

# ខ្ញុំចង់លេងតែអានេះ

Kim Sokna

Phann Sokheng

Let's Read
The Asia Foundation



ព្រឹកថ្ងៃអាទិត្យនេះ សុភាពអង្គុយចុចទូរស័ព្ទយ៉ាងច្រើនម៉ោង។

សុភាព៖ បាញ់! បាញ់! ចូល! ចូល! គេច! គេច!



មីងសុភី ៖ សុភាពល្មមឈប់លេងទូរស័ព្ទហើយ។ កូនប្រញាប់ទៅញ៉ាំបាយទៅ។
សុភាព៖ ចាំមួយភ្លែតសិនម៉ែ!
ខ្ញុំលេងបន្តិចទៀតសិន។



មួយសន្ទុះក្រោយមក...

មីងសុភី៖ សុភាព! ទៅញ៉ាំបាយទៅកូន។

សុភាព៖ ចាំមួយភ្លែតសិនម៉ែ! ខ្ញុំលេងបន្តិចទៀតសិន។



មីងសុភី ៖ មិនបានទេ! កូនត្រូវតែញ៉ាំបាយសិន។

សុភាព៖ ទេ ! ខ្ញុំមិនញ៉ាំទេ! ខ្ញុំចង់លេងទៀត។



សុភាពមិនព្រមញ៉ាំបាយ ក៏រត់ចូល
ទៅក្នុងបន្ទប់បាត់។



តុក ! តុក ! តុក
មីងសុភី៖ សុភាព! ទៅលេងសួនកុមារជាមួយប្អូនស្រីឯងទេ?
សុភាព៖ ខ្ញុំមិនទៅទេ! ខ្ញុំចង់លេង
ទូរស័ព្ទវិញ។



ល្ងាចនោះ...

សុផា៖ បងភាព! លេងកូនដំរីជាមួយខ្ញុំទេ?

សុភាពគ្រវីក្បាល។

សុផា៖ ថ្ងៃមិញ ខ្ញុំបានឃើញសត្វដំរីមែនទែន។

ខ្លួនវាធំណាស់ បងអើយ!

សុភាពគិតក្នុងចិត្ត ៖ ស្តាយណាស់ មិនបានឃើញសត្វដំរីដូច
ប្អូន។



បន្ទាប់ពីញ៉ាំបាយហើយ សុភាពដើររកទូរស័ព្ទ ប៉ុន្តែគេរកមិនឃើញ។



លុះស្អែកឡើង មានមិត្តភក្តិ២-៣នាក់ បានមកបបួល សុភាព ទៅលេងទាត់បាល់។ មិត្តភក្តិ ៖ សុភាព! ទៅលេងទាត់បាល់ជាមួយគ្នាទេ?

សុភាព ៖ ខ្ញុំមិនលេងទេ! ខ្ញុំចង់លេងទូរស័ព្ទវិញ។



សុភាពនៅតែខិតខំរកទូរស័ព្ទម្តងទៀត ប៉ុន្តែគេរកមិនឃើញដដែល។



ខ្ញុំមិនដឹងលេងអីទេ។ ខ្ញុំចង់លេងទូរស័ព្ទ តែអត់មានទូរស័ព្ទ។
សុផា ហៅលេងដំរីជ័រ តែខ្ញុំមិនចង់លេង។
មិត្តភក្តិហៅលេងទាត់បាល់ តែខ្ញុំមិនចង់លេង។





សុភាព ៖ អេ ! ទាំងអស់គ្នា ខ្ញុំសុំលេងទាត់បាល់ដែរបានទេ?
មិត្តភក្តិ៖ តោះសុភាព! យើងលេងជាមួយគ្នា។



សុភាព លេងទាត់បាល់ជាមួយមិត្តភក្តិយ៉ាងសប្បាយរីករាយ។



សុភាព៖ សុផា! បងសុំលេងដំរីជ័រដែរបានទេ?

សុផា៖ តោះបង! យើងលេងជាមួយគ្នា។



សុភាព លេងដំរីជ័រជាមួយប្អូនស្រីយ៉ាងសប្បាយរីករាយ។



ម៉ែ! ខ្ញុំឈប់ចង់លេងទូរស័ព្ទហើយ។ តាមការពិត លេងអ្វីក៏សប្បាយដែរ មិនចាំបាច់លេងទូរស័ព្ទទេ។





Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*ខ្ញុំចង់លេងតែអានេះ*, Author: Kim Sokna. Illustrator: Phann Sokheng. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/